UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

**ផ្តល់អំណាចដល់សំលេងរបស់ជនជាតិដើមភាគតិច**

ប្រដាប់ដោយសេចក្តីក្លាហាន និងសាមគ្គីភាពជាមួយសហគមន៍ជនជាតិដើមភ្នងនានា អ្នកភូមិក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគីរី បានដើរជាក្បួនទៅកាន់ក្រុមហ៊ុនឯកជនមួយ ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច សម្រាប់ដំណាំកៅស៊ូនៅលើដីប្រពៃណីរបស់ពួកគេ។ ប្រឈមមុននឹងបុគ្គលិកនានារបស់ក្រុមហ៊ុន ពួកគេបានបន្លឺសំលេងរួមគ្នាយ៉ាងច្បាស់លាស់ ដើម្បីទាមទារពីក្រុមហ៊ុនថា "យើងមកទីនេះដើម្បី យកដីរបស់យើងវិញ។ អ្នកប្រើប្រាស់ភាពក្រីក្រមកធ្វើអាជីវកម្ម ប៉ុន្តែអ្នកកំពុងយកដី ដែលជាកម្មសិទ្ធិស្របច្បាប់របស់យើង"។

ការអំពាវនាវឲ្យមានការផ្លាស់ប្តូរនៃសហគមន៍ភ្នងនេះ គឺជាទឡ្ហីករណ៍នៃចលនាកាន់តែកើនឡើង របស់ជនជាតិដើមភាគតិចនៅទូទាំងពិភពលោក ដែលនាបច្ចុប្បន្ននេះកាន់តែយល់ដឹងអំពីសិទ្ធិរបស់ពួកគេ ក្នុងការអភិរក្សវប្បធម៌ ដីធ្លី ភាសា និងសាសនារបស់ពួកគេ។ បាតុភូតនេះកើតចេញពីការតស៊ូដ៏យូរយាដើម្បី ស្វែងរកការទទួលស្គាល់សិទ្ធិមនុស្សនៃជនជាតិដើមភាគតិច ដែលនាំដល់ការអនុម័ត សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច កាលពីប្រាំឆ្នាំកន្លងទៅ។ សេចក្តីប្រកាស ដែលរដ្ឋជាសមាជិកចំនួន១៤៣បានបោះឆ្នោតគាំទ្រ (រួមបញ្ចូលកម្ពុជា) តំណាងទសវត្ស ចុងក្រោយនៃការតស៊ូមតិសម្រាប់សិទ្ធិជនជាតិដើមភាគតិច និងកំណត់យ៉ាងជាក់លាក់ អំពីសិទ្ធិខាងដីធ្លី វប្បធម៌ ការចិញ្ចឹមជីវិត និងការពិគ្រោះយោបល់ ក្នុងចំណោមសិទ្ធិផ្សេងៗទៀត។ ដោយមានការទទួលស្គាល់ ជាសកលនូវសិទ្ធិរបស់ពួកគេនៅក្នុងដៃ សហគមន៍ជនជាតិដើមភាគតិចនានាបានសម្រេចបាននូវ សម្មិទ្ធិផលគួរឲ្យកត់សំគាល់ជាច្រើន នៅក្នុងការកំណត់អត្តសញ្ញាណជាសហគមន៍ ប្រព័ន្ធគ្រប់គ្រង ការអប់រំ និងនៅក្នុងការទាមទារសិទ្ធិរបស់ពួកគេ ដោយដាក់ផលប្រយោជន៍របស់ពួកគេយ៉ាងជោគជ័យ ទៅក្នុងរបៀបវារៈ។ ក្នុងឱកាសនៃទិវាអន្តរជាតិនៃជនជាតិដើមភាគតិចពិភពលោកនៅថ្ងៃនេះ យើងសូមអបអរសាទរសម្មិទ្ធិផលទាំងអស់នេះ។

ជាក់ស្តែងដូចជាសកម្មភាពរបស់ជនជាតិដើមភាគតិចនៅប៊ូស្រា សហគមន៍នេះបាននឹងកំពុងចុះល្បាត នៅព្រៃឡង់ ព្រមទាំងជោគជ័យនៃប្រជាជនសួយ ក្នុងការធានាការពារព្រៃ៣០០០ហិតានៅក្នុងខេត្តកំពុងស្ពឺ បង្ហាញថាកម្ពុជាក៏មិនខុសពីប្រទេសដទៃទៀតដែរនៅក្នុងនិន្នាការនេះ។ ដោយមានជនជាតិដើមភាគតិច ប្រមាណជាង១០០០០០នាក់ ក្នុងចំណោម២៤ក្រុមខុសៗគ្នា នៅទូទាំងខេត្តចំនួន១៥ ព្រះរាជាណាចក្រនេះ មានជនជាតិដើមភាគតិចចម្រុះយ៉ាងសម្បូរបែប។ ដូចគ្នានឹងជនជាតិដើមភាគតិចនៅទូទាំងពិភពលោកដែរ

ទំនាក់ទំនងរបស់សហគមន៍ទាំងនោះជាមួយទឹកដីព្រៃឈើរបស់ពួកគេគឺជាមូលដ្ឋានក្នុងកំណត់អត្តសញ្ញាណពួកគេជាជនជាតិដើមភាគតិច។ ការរក្សាការពារទឹកដីដូនតាចាក់ឫសយ៉ាងជ្រៅនៅក្នុងការគោរពសក្ការៈរបស់ជនជាតិដើមភាគតិច ចំពោះធម្មជាតិ និងការពឹងអាស្រ័យលើធនធានដីធ្លីរបស់ពួកគេ សម្រាប់ការទ្រទ្រង់ជីវិត។
មាត្រា១០នៃសេចក្តីប្រកាសជាសកលអ.ស.ប ហាមឃាត់ការបណ្តេញជនជាតិដើមភាគតិច ចេញដោយបង្ខំពីដីធ្លី និងដែនដីរបស់ពួកគេ និងរារាំងមិនឲ្យមានការប្តូរទីលំនៅថ្មីដោយគ្មានការព្រមព្រៀងដោយសេរី និងជូនដំណឹងជាមុន រួមទាំងសំណងត្រឹមត្រូវនិងយុត្តិធម៌សម្រាប់គ្រប់ប្រជាជន ដែលរងប៉ះពាល់។ នៅកម្ពុជានាពេលបច្ចុប្បន្ននេះ ក៏ដូចជានៅក្នុងប្រទេសផ្សេងៗដទៃទៀតដែរ សហគមន៍ជនជាតិដើមភាគតិច ត្រូវទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយទំនាស់ដីធ្លី ដីរាតត្បាត និងរុករ៉ែ។ ទំនាស់ដីធ្លីទាំងនេះគម្រាមកំហែងដល់ជនជាតិដើមភាគតិច ដោយការប្តូរលំនៅថ្មី និងដាក់ការចិញ្ចឹមជីវិតរបស់ពួកគេក្នុងហានិភ័យ។ ទំនាស់ដីធ្លីក៏អាចបង្ហាញនូវការមិនអើពើនឹងកេរ្តិ៍តំណែលខាងវប្បធម៌ សាសនា និងដួងព្រលឹង ហើយអាចរហូតដល់បណ្តាលឲ្យបាត់បង់ភាពចម្រុះនៃពូជសាសន៍។

ក្នុងចំណោមទំនាស់ដីធ្លីទាំង៦៣ ដែលការិយាល័យOHCHR ត្រូវបានស្នើឲ្យជួយកាលពីឆ្នាំកន្លងទៅ ២០%មានជាប់ទាក់ទងនឹងដីធ្លីជនជាតិដើម ទោះបីជាសហគមន៍ជនជាតិដើមភាគតិច តំណាងឲ្យតែ១%នៃចំនួនពលរដ្ឋកម្ពុជាក៏ដោយ។

ទោះជាដូច្នោះក៏ដោយ ក្របខ័ណ្ឌច្បាប់សម្រាប់ការការពារដីធ្លីនៃជនជាតិដើមភាគតិច ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាត្រូវបានរៀបចំបង្កើតឡើងយ៉ាងល្អិតល្អន់។ បើប្រៀបធៀបនឹងប្រទេសផ្សេងៗទៀត ជនជាតិដើមភាគតិចនៅកម្ពុជាបានដំណើរការ យ៉ាងច្បាស់លាស់គួរសម ប្រសិនបើលំបាកពេក ក្នុងការធ្វើតាម ដើម្បីឲ្យពួកគេអាចទទួលបាន ការទទួលស្គាល់ថាជាសហគមន៍ជនជាតិដើមភាគតិច ចុះឈ្មោះជានីតិបុគ្គល និងទាមទារកម្មសិទ្ធិសមូហភាពលើដីធ្លីព្រៃឈើរបស់ពួកគេ។
កម្មសិទ្ធិសមូហភាពគឺជាមធ្យោបាយដ៏រឹងមាំបំផុតរបស់សហគមន៍ ក្នុងការទប់ទល់នឹងការរំលោភយកដីធ្លី។ ក្នុងចំណោមគម្រោងដែលគាំទ្រដោយម្ចាស់ជំនួយជាច្រើនផ្សេងៗទៀត ការិយាល័យOHCHR រួមជាមួយរដ្ឋាភិបាល ILO និងសង្គមស៊ីវិល កំពុងជួយដល់សហគមន៍ជនជាតិភ្នងចំនួន៧ នៅឃុំប៊ូស្រា ក្នុងខេត្តមណ្ឌលគីរី និងសហគមន៍សួយចំនួនប្រាំនៅខេត្តកំពុងស្ពឺ នៅក្នុងដំណើរការនេះ។ បទពិសោធន៍បង្ហាញថា ដំណើរការនេះក៏បម្រើដល់ការអប់រំសហគមន៍ជនជាតិដើមភាគតិច អំពីសិទ្ធិរបស់ពួកគេ ពង្រឹងដល់សិនិទ្ធពលរបស់ពួកគេ និងរឹតចំណងសាមគ្គីភាពជាមួយសហគមន៍ផ្សេងៗទៀត ដែលដីធ្លីរបស់ពួកគេប្រឈមនឹងការគម្រាមកំហែងតាមទម្រង់ផ្សេងៗនៃការរំលោភយកដីធ្លី។

ការចងក្រងជាទ្រង់ទ្រាយធំនៃសហគមន៍ជនជាតិដើមភាគតិចនានា ក្នុងការទាមទារសិទ្ធិរបស់ពួកគេ ត្រូវបានគាំទ្រនៅក្នុងផ្នែកជាច្រើននៃពិភពលោក ដោយការកើនឡើងនៃប្រព័ន្ធផ្សព្វផ្សាយ ជនជាតិដើមភាគតិច ជាពិសេសវិទ្យុ និងល្ខោន។ ប្រព័ន្ធផ្សព្វផ្សាយជនជាតិដើមភាគតិច ដែលជាប្រធានបទនៃទិវាអន្តរជាតិឆ្នាំនេះ អាចជាឧបករណ៍ដ៏មានឥទ្ធិពល ក្នុងការទាមទារសិទ្ធិមនុស្ស និងបញ្ជ្រាបសំលេងជនជាតិដើមភាគតិច នៅក្នុងសង្គមជាតិទាំងមូល។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះបម្រើជាមធ្យោបាយ មិនសម្រាប់តែសហគមន៍ជនជាតិដើមភាគតិច ប៉ុណ្ណោះនោះទេ ក្នុងការទាក់ទាញចំណាប់អារម្មណ៍ចំពោះការរំលោភលើសិទ្ធិរបស់ពួកគេ ប៉ុន្តែវាមានសារសំខាន់ដើម្បីបង្ហាញឲ្យឃើញនូវទឡ្ហីករណ៍ប្រចាំថ្ងៃនៃជោគជ័យតូចៗ ដែលឈ្នះដោយសហគមន៍ជនជាតិដើមភាគតិចនៅក្នុងការការពារសិទ្ធិរបស់ពួកគេ។

ខណៈដែលប្រព័ន្ធផ្សព្វផ្សាយជនជាតិដើមភាគតិចនៅកម្ពុជាស្ថិតនៅដំណាក់កាលក្មេងខ្ចីនៅឡើយ ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតក៏ដើរតួនាទីសំខាន់ដែរក្នុងការបញ្ជ្រាបសំលេងរបស់ពួកគេ។ នៅទិវាអន្តរជាតិនេះ លោកបាន គីមូន អគ្គលេខាធិការអ.ស.ប បានអំពាវនាវដល់ "រដ្ឋជាសមាជិកនានា និងប្រព័ន្ធផ្សព្វផ្សាយឲ្យបង្កើត និងរក្សាកាលានុវត្តភាពសម្រាប់ជនជាតិដើមភាគតិច ក្នុងការសម្តែងមតិយ៉ាងច្បាស់អំពីទស្សនវិស័យ អាទិភាព និងសេចក្តីប្រាថ្នាចង់បានរបស់ពួកគេ"។ កាលានុវត្តភាពបែបនេះត្រូវបានបង្កើតដោយរាជរដ្ឋាភិបាលកម្ពុជារួចហើយ ដែលបានសហការជាមួយ UNESCO ក្នុងការផ្តល់វិទ្យុផ្សព្វផ្សាយក្នុងខេត្តរតនគីរី ជាភាសាគ្រឹង ទំពួន ព្រៅ និងចារ៉ៃ។ មានតែការផ្តួចផ្តើមបែបនេះច្រើនទៀត ជាពិសេសប្រព័ន្ធផ្សព្វផ្សាយដែលកាន់កាប់ និងគ្រប់គ្រងដោយជនជាតិដើមភាគតិច ទើបអាចពង្រឹងសំលេងសហគមន៍ជនជាតិភាគតិច នៅកម្ពុជាក្នុងការទាមទារសិទ្ធិរបស់ពួកគេបាន។

លោក **ជេមស៍ ហ៊ីណិន** តំណាងស្ដីទីនៃការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា